# ការសម្ភាសន៍របស់កុង សុខ សឿន

កៈ អ្នកដែលសម្ភាសន៍ រត្ន ពិសី ខៈ អ្នកដែលត្រូវគេបានសម្ភាស់ន៍ សុខ សឿន

**ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់គុង សុខ សឿន**

ការសម្ភាសន៍សង្ខេបជីវប្រវត្តិរបស់លោកតា សុខ សឿន ដែលគាត់មានការជួបហើយមានការឆ្លងកាត់ពីសម័យសង្គ្រាមដល់ជូរជត់មួយហើយដែលគាត់មិនអាចបំផ្លាចបាននៅភាពជូរជត់ហើយមានការលំបាកជាច្រើននៅក្នុងជីវិតរបស់គាត់ហើយគាត់ជាមនុស្សដែលមានការស្លូតបូតហើយមានការអត់ធ្មត់នៅក្នុងជីវិតរបស់គាត់ហើយគាត់មានការមេត្តា ករុណា ដល់កូនចៅជំនាន់ក្រោយរបស់គាត់។ធ្វើនៅភូមិ កោះឧញ្ញាតី ស្រុក ស្អាង ខេត្ត កណ្តាលធ្វើនៅថ្ងៃទី ០២ ខែ ០៦ ឆ្នាំ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរគុងខ្ញុំបាទមានឈ្មោះ រត្ន ពិសី ដែលបានសូមការអនុញ្ញាតធ្វើការសម្ភាសន៍គុងមានឈ្មោះ សុខ សឿនដោយបានធ្វើឡើងដោយសាកលវិទ្យាល័យមួយដែរមានឈ្មោះថាសាកលវិទ្យាល័យ B Y U ដែរមានទីតាំងនៅអាមេរិចគេចងដឹងពីជីវប្រវត្តិរបស់គុងដើម្បីថែរក្សាជីវប្រវត្តិរបស់គុងទុកអោយកូចៅជំនាន់ក្រោយរបស់គុងឲ្យពួកគាត់បានស្តាប់ថាអ្នកជំនាន់មុនមានការលំបាកអ្វីខ្លះហើយដើម្បីថែរក្សាជីវប្រវត្តិជូនតារបស់គុងផងដែល។ហើយឲ្យគាត់បានដឹងថាអ្នកជំនាន់មុនមានការលំបាកណាស់។

បាទ!ចឹងខ្ញុំបានធ្វើឡើងនៅថ្ងៃទី ០២ ខែ ០៦ ឆ្នាំ ២០១៨

កៈ បាទ!ចឹងតើគុងមានឈ្មោះអ្វីដែលគុង?

ខៈ ខ្ញុំមានឈ្មោះថា សុខ សឿន។

កៈ បាទ!ចឹងគុងសព្វថ្ងៃនឹងតើគុងមានអាយុប៉ុន្មានហើយគុង?

ខៈ ខ្ញុំមានអាយុ៧៨ឆ្នាំ។

កៈ បាទ!ចឹងគុងមានអាយុ៧៨ឆ្នាំហើយបាទចឹងគុងមានចាំថ្ងៃខែឆ្នាំកំណើតរបស់គុងផ្ទាល់ណាស់តើគុងនៅចាំទេគុងថ្ងៃណាខែណាឆ្នាំណាគុង?

ខ៖ ខ្ញុំអត់ចាំទេ។

ក៖ បាទ!គុងភ្លេចហើយបាទចឹងបើឆ្នាំខ្មែរវិញតើគុងមាននៅចាំទេ?

ខ៖ ឆ្នាំខ្មែរខែចេះឆ្នាំម្សាញ់។

ក៖ បាទ!ចឹងគុងឆ្នាំម្សាញ់បាទ!ចឹងគុងតើនៅនឹងគេហៅភូមិអីដែលគុង?

ខ៖ ភូមិកោះឧញ្ញាតីស្រុកស្អាងខេត្តកណ្ដាល។

ក៖ បាទ!ចឹងឃុំអីគេដែលគុង?

ខ៖ ឃុំកោះឧញ្ញាតីដែល។

ក៖ បាទ!ឃុំកោះឧញ្ញាតីដែលគុង?

ខ៖ ឃុំកោះឧញ្ញាតីដែល។

កើ អរបាទ!ចឹងជាមួយគ្នាដែលចឹងគុងមានចាំទីកន្លែងកំណើតរបស់គុងផ្ទាល់ទេគុង?

ខ៖ ខ្ញុំកើតនៅខេត្តនឹង។

ក៖ អរបាទ!ចឹងគុងស្រុកកំណើតរបស់គុងនៅនឹងម៉ងគុង?

ខ៖ បាទ!

ក៖ បាទ!ចឹងគុងកើតនៅនឹងស្រុកកំណើតរបស់គុងនៅនឹងស្រាប់ម៉ង?

ខ៖ បាទ!

ក៖ បាទ!ចឹងតើគុងមានបងប្អូនបង្កើតប៉ុន្មាននាក់ដែលគុង?

ខ៖ ខ្ញុំមានបងប្អូនបង្កើត៣នាក់។

ក៖ អរបាទ!ចឹងគុងមានបងប្អូនបង្កើ៣នាក់បាទចឹងតើគុងជាកូនទីប៉ុន្មានដែលគុង?

ខ៖ ខ្ញុំជាកូនទី៣។

ក៖ អរចឹងគុងជាកូនពៅ?

ខ៖ បាទ!ខ្ញុំជាកូនពៅ។

កៈ បាទ!ចឹងតើគុងនៅចាំឈ្មោះបងប្អូនរបស់គុងទេ?

ខៈ បាទ!ខ្ញុំចាំតា។

កៈ បាទ!តើពួកគាត់មានឈ្មោះអ្វីដែលគុង?

ខៈ បងខ្ញុំបងស្រីគាត់មានឈ្មោះ សន បងសីហើយបន្ទាប់មកខ្ញុំជាកូន៣។

កៈ បាទ!ហើយគុងជាកូនទី៣?

ខៈ បាទ!។

កៈ
បាទ!ចឹងតើគុងនៅចាំសាច់រឿងជាមួយពួកគាត់ធ្លាប់ទៅណាអីជាមួយគ្នាចឹងណាស់គុងតើគុងមាននៅចាំទេ?

ខៈ កាលពីអាពតនឹងទៅនៅភូមិឃុំខេត្តគេនឹងខេត្តគេនឹង។

កៈ បាទ!តើនៅខេត្តណាដែលគុង?

ខៈ នៅដល់ពោធិសាត់អស់។

កៈ អរគុងទៅនៅដល់ពោធិសាត់?

ខៈ ទៅនៅពោធិសាត់ បាត់ដំបង អាពតវាជំលៀសណាស់។

កៈ បាទ!ចឹងពេលនឹងគុងមានអាយុប៉ុន្មានហើយគុង?

ខៈ កាលនឹងខ្ញុំមានអាយុ២០ទៅ២៨ឆ្នាំហើយ។

កៈ អរ២៧ ២៨គេមានចាប់គុងធ្វើទាហានទេគុង?

ខៈ អតទេ។

កៈ អតទេគុងបាទចឹងគុងពេលជំនាន់នឹងគេអោយគុងធ្វើអីគេខ្លះទៅគុង?

ខៈ កាលនឹងខ្ញុំដូចជាផុតកាលនឹងខ្ញុំខាងនេសាទអីចឹងទៅកាលនឹង។

កៈ អរគេអោយគុងជីកដីជីកអីទេគុង?

ខៈ អរកាលនឹងគេអោយជីកដីកន្លែងណាក៏ជីកដែលដូចជីកដីធ្វើផ្លូវអីចឹង។

កៈ បាទ!អោយយើងធ្វើស្រែអីទៅ?

ខៈ
ធ្វើស្រែផងធ្វើផ្លូវផងដូចថាវាអោយផ្លូវចឹងណាស់ទៅកាប់ភ្នំកាលនឹងវៀតតានៀលណាស់។

កៈ កាលនឹងវៀតតានៀលគុងជាមួយបងប្អូនគុងទៅ?

ខៈ
បាទ!នៅភ្នំដងរែកកាលនឹងវៀតតានៀលណាស់អ្នកស្លាប់ទាំងស្រស់វាយកទៅសម្លាប់ចោ
យើញនឹងភ្នែកនឹងណាស់តាយើងនិយាយខុសមួយមាត់អីវាថាឯងនឹងអីណា។

កៈ ជនជាតិវៀតណាមមែនគុង?

ខៈ អត់ខ្មែរយើងនឹង។

កៈ គាត់ថាយើងមើលងាយគេមែនគុង?

ខៈ គេថាយើងបផុសបផលអីនឹង។

កៈ បាទ!គេថាយើងបផុសបផលចឹងគេយកយើងទៅសម្លាប់ចោលចឹងណាស់?

ខៈ វានិយាយមួយមាត់ថា
ភ្ញូកនៅពីក្រោយខ្នងដល់ម៉ោង៦ខ្ញុំចេញពីធ្វើការមកបានបញ្ចូញខ្ញុំទៅគុកជិត១២នាក់១០នា
ក់អីចឹងវាថាយើងធ្វើការខ្ញុំខំប្រឹងធ្វើការចង់ងាប់ក្រោនតែខ្ញុំស្មោះទឹកមាត់នឹងក៏វារករឿងយើ
ងដែលវារកតារឿងយើងយកទៅសម្លាប់ចោលនឹង។

កៈ បាទ!ពិបាកណាស់គុងនិយាយក៏មិនបានអីក៏ពិបាកណាស់គុង?

ខៈ
កាលពីជំនាន់អាពតនឹងខ្លាំងមែនទេនម៉ងណាស់គ្មានពីណាដូចទេគ្មានរបបណាដូចយើង
ទេគេអោយអីយើងស៊ីគេប្រើយើងពេលភ្លៀងក៏ទៅតាបាក់ទំនប់នឹង។

កៈ បាទ!គេអោយទៅជីកដីបិតទំនប់ទៅ?

ខៈ បាទ!គេអោយជីកដីបិតទំនប់ទៅវៀតតានៀលណាស់។

កៈ បាទ!ចឹងតើគុងគេមានអោយគុងជីកប្រលែយទេ?

ខៈ នឹងជីកប្រលែននឹង។

កៈ បាទ!ចឹងគុងមាននៅចាំថាគេអោយជីកប្រវែងណាទេគុង?

ខៈ គេអោយជីក១០០មិតជាង។

កៈ អរពេលនឹង១០០មិតជាងនឹងតើប៉ុន្មានមែតដែលគុង?

ខៈ ១០០ម៉ែត្រយើងដែលនឹង។

កៈ អរចឹង១០០មិតនឹងស្មើ១០០ម៉ែត្រយើងដែលគុង?

ខៈ បាទ!

កៈ អរ១០០មិតចឹងស្មើ១០០ម៉ែត្រ?

ខៈ ១០០ម៉ែត្រជាងនឹង។

កៈ បាទ!ចឹងគេអោយគុងជីកទៅរហូតទៅ?

ខៈ បាទ!នឹងហើយជីកពៃយើងនឹងចាក់ពៃពីរសណ្ឋុងយើងនឹង។

កៈ បាទ!ជ្រៅគុង?

ខៈ បាទ!ជ្រៅដែលនឹងគេហៅថាជីកប្រឡៃយទឹក។

កៈ បាទ!គេហៅថាជីកប្រឡៃយទឹក?

ខៈ នឹងហើយ។

កៈ គេមិនមែនហៅប្រឡៃយទឹកទេគុងអណ្ដៅកប់យើងវិញទេគុង?

ខៈ
អត់ទេអានឹងដោយខ្លួនអាមួយអណ្ដៅកប់យើងតែវាមិនប្រាប់យើងថាអណ្ដៅកប់យើងទេណាស់។

កៈ បាទ!វាថាអណ្ដៅប្រឡៃយទឹក?

ខៈ បាទ!នឹងហើយ។

កៈ តាមពិតកប់យើងទេ?

ខៈ កប់យើងនឹងវាផររហូត។

កៈ បាទ!វាផររហូតវាផរយើងចេះតែធ្វើទៅបានអង្ករញ៉ាំ?

ខៈ
តាយើងអត់សិល្បធម៍វិញដឹងថាអត់បាយហើយវាល្អយ៉ាងដែលយើងគិតទៅវាពេះពាល់គ្នាអីវាអត់អីវិញវាការអោយដែលប៉ុន្តែយើងចង់បានចឹងយើងស្នើទៅគេរៀបគូរៗណាស់មួយគូរកាលណារៀបការម្តងកាប់គោនៅភ្នំនៅសម្បូររម៉ែង គោព្រៃអី៥ ១០ ២០អីណាស់ដល់ហើយមកគ្រប់ភូមិគ្រប់ខេត្តអីណាស់។

កៈ បាទ!ចឹងគុងគេអត់មានបានជ្រៀសទៅណាទៀតទេគុង?

ខៈ ខ្ញុំកាលនឹងខ្ញុំនៅច្បាលអំពៅទៅបានខ្ញុំតៅខាងគគីរផ្សាគគីរធំណាស់។

កៈ បាទ!

ខៈ
រួតទៅបានខ្ញុំទៅកំពុងធំដាក់កាណ្ឌូតទៅកំពុងធំរួតទៅបានទៅព្រះវិហារទៅបានទៅដាក់តាមជើងភ្នំអីនឹងកាលនឹងវៀតតានៀលណាស់ដើរមួយថ្ងៃៗដើរអត់មានឈប់។

កៈ បាទ!គេអត់មានអោយយើងឈប់ម៉ងគុង?

ខៈ នឹងហើយដើរថ្នាក់ទៀត។

កៈ បាទ!តាមមួយថ្នាក់មួយថ្នាក់?

ខៈ កាលនឹងឈឺអីរត់បាត់អស់ហើយ។

កៈ បាទ!តែកាលនឹងអត់ឈឺទៀតណាស់?

ខៈ ឈឺក៏ចេះតែទៅទៀតណាស់។

កៈ បាទ!ទោះឈឺក៏គ្មានថ្នាំលេបដែលគុងណាស់?

ខៈ ថ្នាំវាមានតា។

កៈ អរថ្នាំគេមានដែលគុង?

ខៈ
ថ្នាំអាចទន្សាយថ្នាំនឹងគេយកមកគ្រាបទឹកទៅវាយកទៅស្ងោទឹក៣យកទឹក១ទៅទឹក១ទៅទឹកកន្លះចឹងទៅនឹងហើយគេពុំគេធ្វើពុំទៅសបកកៅស៊ូរនឹងដាក់ជាប់គ្នានឹងគេដាក់ថ្នាំពីបាតខ្ទាស់មកគេដងចាក់ដងចាក់។

កៈ បាទ!គេដងចាក់អោយយើងផឹកទៅ?

ខៈ
អត់ទេដងចាក់ដងចាក់នឹងយើងយកមកលេបទៅដូចអាសភារីងចឹងណាស់និយាយទៅថ្នាំគ្រាប់នឹងណាស់យើងឈឺទៅលេប៤ទៅ៥គ្រាប់ជូនការលេងមួយដៃអីចឹងយើងទៅណាញីញូលនឹងពិនតែធ្វើការខ្លាំងដែលជូនការមិនសូវមានអ្នកស្លាប់អីម៉ានផងអ្នកដែលស្លាប់នឹងវាយកទៅវៃចោលនឹងអាលែងពួកខូតសិល្បធន៍នឹងស៊ីក៏មិនបានឆ្អែតអីដែលជំឡុងជ្វារយើងនឹង។

កៈ បាទ!បានជំឡុងដូចបានសាច់គោចឹង?

ខៈ នឹងហើយអរណាស់កន្លះខែអីមិនទាន់បានស៊ីម្តងផង។

កៈ បាទ!បានពោតដូចបានសាច់ជ្រូកចឹងគុង?

ខៈ ពោតនឹងដល់ហើយអរណាស់។

កៈ បាទ!បើមួយថ្ងៃៗបានតាបបរ?

ខៈ បបរនឹងគេចែកអោយតាមួយនាក់មួយកានឹង។

កៈ បាទ!

ខៈ មួយកានឹងពេលធ្វើការនឹងគេវៃជួងរើអ្វីដែលសំខាន់គឺស្រឹកព្រាជាមួយបបរ។

កៈ បាទ!

ខៈ
ដាក់ខ្សែចង់ខ្ញុំនឹកឃើញថាស្រុកខ្មែរមិនដល់ពិននឹងសោះអរមាសគេយកទៅណាគេយកមាសទៅធ្វើខ្សែកណ្តឹងគោណាវាហាលណាស់គ្មានពីណាគេពាក់អីទេ។

កៈ បាទ!គ្មានពីណាគេប្លន់ទេកុង?

ខៈ បាទ!គ្មានពីណាគេប្លន់ទេ។

កៈ
បាទ!កាលនឹងរកតាព្រះអាយោះសខ្លួនឯងមិនរួតផងនឹងបាទចឹងគុងមានចាំឈ្មោះឪពុកម្តាយរបស់គុងទេ?

ខៈ ខ្ញុំចាំតា។

កៈ បាទ!ចឹងតើពួកគាត់មានឈ្មោះអីគេខ្លះដែលកុងឈ្មោះឪពុកម្តាយគុងណាស់?

ខៈ ឪពុកខ្ញុំឈ្មោះ កាម ម៉ែ ។

កៈ បាទ!ទាំងត្រកូរគាត់?

ខៈ ត្រកូរគាត់ឈ្មោះសុខ កាម ម៉ែ។

កៈ បាទ!ចឹងឈ្មោះម្តាយកុង?

ខៈ ម្តាយខ្ញុំឈ្មោះ យាយពុយ ។

កៈ បាទ!ចឹងគុងមានចាំថាគាត់មានអាយុប៉ុន្មានដែលគុង?

ខៈ កាលគាត់បែកពីខ្ញុំទៅគាត់ស្លាប់នៅព្រៃវែងណាស់។

កៈ អរគាត់ទៅស្លាប់នៅព្រៃវែងគុង?

ខៈបាទ!

កៈ បាទ!តែពេលនឹងតើគាត់មានអាយុប៉ុន្មានដែលគុង?

ខៈ កាលនឹងគាត់មានអាយុចូល៦៥ធីនឹង។

កៈ អរគាត់មានអាយុ៦៥ឆ្នាំហើយគុង?

ខៈ បាទ!៦៥ ៧៥ ។

កៈ បាទ!អរចឹងលោកឪពុក៧៥ឆ្នាំហើយគុង?

ខៈ បាទ!

កៈ បាទ!ចឹងអ្នកម្តាយ ៦៥ឆ្នាំ លោកឪពុក ៧៥ឆ្នាំ?

ខៈ បាទ!

កៈបាទ!ចឹងតើគាត់បានស្លាប់ដោយសារជំងឺឬមួយក៏គេយកគាត់ទៅសម្លាប់ចោលគុង?

ខៈ គេអត់មានយកគាត់ទៅសម្លាប់ទេគាត់ស្លាប់ដោយសារអត់បាយ។

កៈ អរគាត់អត់បានបាយគុង?

ខ៖ បាទ!គាត់អត់បានបាយគាត់ហូបតែបបរ។

ក៖ បាទ!ហូបអត់បានគ្រប់គ្រាន់ចឹងទៅគាត់ក៏ស្លាប់ទៅ?

ខ៖ បាទ!គាត់ហូបអត់បានគ្រប់គ្រាន់។

ក៖ បាទ!គាត់ក៏ស្លាប់ទៅ?

ខ៖ បាទ!

ក៖ បាទ!ចឹងតើគុងមានចាំថាតើគាត់មានឆ្នាំអ្វីដែលគុង?

ខ៖ ឆ្នាំខ្មែរនឹង។

ក៖ បាទ!ៗ

ខ៖ ឆ្នាំមមែ។

ក៖ បាទ!លោកឪពុកគុង?

ខ៖ បាទ!

ក៖ ហើយចុះអ្នកម្ដាយវិញគុងតើគាត់កើតឆ្នាំអីដែលគុង?

ខ៖ អ្នកម្ដាយខ្ញុំគាត់ឆ្នាំរក។

ក៖ បាទ!ឆ្នាំរកគុង?

ខ៖ បាទ!

ក៖ បាទ!អ្នកម្ដាយឆ្នាំរកលោកឪពុកឆ្នាំមមែ?

ខ៖ បាទ!

ក៖
បាទ!ចឹងគុងតើគាត់មានដែលធ្លាប់ប្រាប់គុងថាគាត់ជាអ្នកមកពីខេត្តណាអីចឹងណាស់គុង?

ខ៖ គាត់នៅខេត្តកណ្ដាល។

ក៖ អរអ្នកម្ដាយនៅខេត្តកណ្ដាលដែល?

ខ៖ បាទ!

កៈ
បាទ!ចឹងលោកឪពុកជាអ្នកនៅខេត្តកណ្តាលអ្នកម្តាយជាអ្នកនៅខេត្តកណ្តាលដែលគុង?

ខៈ បាទ!តែគ្រាន់តែភូមិខុសគ្នា។

កៈ អរចឹងភូមិខុសគ្នាគុង?

ខៈ បាទ!ភូមិឃុំខុសគ្នា។

កៈ
បាទ!ចឹងគុងមានចាំថាកាលជំនាន់មុនអាពតនឹងណាស់តើលោកឪពុកអ្នកម្តាយគុងគាត់ប្រកបមិខរបរអ្វីដើម្បីចិញ្ចឹមគុងណាស់?

ខៈ
គាត់ឧស្សាហ៍ណាស់កាលពីដើមគាត់ដីធំណាស់គាត់ធ្វើចំការគាត់ដាំត្រប់ដាំជីរចឹងណាស់។

កៈ អរបាទ!

ខៈ ដល់បានចឹងយើងយកទៅផ្សារទៅក្រោយមកគាត់អាយុ៦០ ៥៨ ឆ្នាំអីគាត់លក់ទៅ។

កៈ បាទ!ហើយចុះអ្នកម្តាយគុង?

ខៈ ម្តាយខ្ញុំគាត់ជាត្បាញអី។

កៈ អរគាត់ជាអ្នកត្បាញអីគេគុងត្បាញហូលផាមួងអីចឹងទៅគុង?

ខៈ គាត់ត្បាញក្រមា។

កៈ អរត្បាញក្រមាគុង?

ខៈ បាទ!

កៈ បាទ!
ចឹងគុងមាននៅចាំសាច់រឿងអីជាមួយគាត់ទេគុងថាដូចជាទៅណាជាមួយគាត់ឬពីកាលជំនាន់អាពតអីចឹងណាស់មានធ្លាប់ជូរជត់ជាមួយគាត់ចឹងណាស់គុង?

ខៈ ខ្ញុំនៅជាមួយគាត់រហូតនឹង។

កៈ អរគុងនៅជាមួយគាត់?

ខ៖ បាទ!បងប្អូន២
៣នាក់នឹងក៏នៅជាមួយខ្ញុំដែលនៅជាមួយគាត់នៅជាមួយគ្នាទាំងអស់នឹងនៅក្នុងផ្ទះនឹង។

ក៖ បាទ!ចឹងតើគុងមានជួបជួរជត់ជាមួយគ្នាទេគុង?

ខ៖ បាទ!ជួរជត់តាពេលពួកអាពតវាចូលមកនឹងវាទៅនៅផ្ទះខ្ញុំនឹង។

ក៖ អរដល់អាពតចូលមកវាទៅនៅផ្ទះគុងម៉ង?

ខ៖ បាទ!នឹងហើយ។

ក៖ បាទ!ចឹងវាអត់មានធ្វើអីគុងណាអីគុង?

ខ៖
អត់ទេវាអត់ធ្វើអីយើងទេអរវាចិត្តសាស្រ្តល្អណាស់យើងអោយអីវាស៊ីទៅណាស់យើងនិយាយមួយវាស្រួលណាស់ខ្ញុំកាលអាយុ១២ឆ្នាំកាលទាន់ជំនាន់អិស្ស្រះវៀតតានៀលណាស់តែមកដល់វាចាប់ឪពុកខ្ញុំមកពីលក់ដូរផ្សារវិញគាត់អង្គុយលើរ៉ឺម៉កនឹង។

ក៖ បាទ!គឺចាប់រឿងអីដែលគុង?

ខ៖
អាពតនឹងវាចាប់រកលុយណាស់ទៅដល់វាធ្វើបាតដែលពួកអាអិស្រះនឹងវារកលុយកាលលុយតថ្លៃណាស់។

ក៖ បាទ!

ខ៖
អោយវាទៅនៅសល់១ម៉ឺនចឹងទៅវាទៅអស់លុយគ្មានអ្នកណាធ្វើបាបទេយើងរកស៊ីចឹងទៅខ្ញុំទាន់ជំនាន់អិស្ស្រះហើយនឹងជំនាន់អាពតនឹង។

ក៖ បាទ!ពេលនឹងជំនាន់អិស្ស្រះគុងមានអាយុប៉ុន្មានហើយគុង?

ខ៖ ខ្ញុំអាយុប្រហែល១១ឆ្នាំ។

ក៖ អរគុងទុបតែអាយុ១១ឆ្នាំនឹងកាលជំនាន់អិស្ស្រះ?

ខ៖ បាទ!

ក៖ បាទ!ហើយកាលជំនាន់អាពតគុងមានអាយុប៉ុន្មានឆ្នាំដែលគុង?

ខ៖ អាជំនាន់អាពតខ្ញុំអាយុ២៨ឆ្នាំ។

ក៖ អរកាលជំនាន់អាពត់គុងមានអាយុ២៨ឆ្នាំ?

ខ៖ បាទ!

ក៖ បាទ!ចឹងគុងគាត់មានដែលប្រាប់ពីខ្សែជីវិត្តកាលគាត់នៅពីក្មេងណាស់គុង?

ខ៖ គាត់មានដែលប្រាប់អីបើគាត់នៅធ្វើចំការនៅនឹងស្រុកគាត់នៅនឹងហើយ។

ក៖ បាទ!

ខ៖ ស្រុកគាត់នៅនិង។

ក៖ បាទ! ស្រុកកំណើតគាត់នៅនិងកុងហើយគាត់មានការជូរជត់នៅនិងដែរកុង។

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ជឹងកុងមានចាំឈ្មោះជីដូនជីតារបស់កុងដូចខាងឪពុកខាងម្តាយអញ្ជឹងកុងមានចាំទេ?

ខ៖ អត់ចាំទេ។

ក៖ បាទ! អញ្ជឹងកុងអត់ចាំទេកុង?

ខ៖ បាទ! ព្រោះវា៧០ឆ្នាំជាងហើយនិង។

ក៖ បាទ! ហើយអញ្ជឹងកុងបងប្អូនបីនាក់របស់កុងនិងគាត់នៅមានប្រជុនរស់សព្វថ្ងៃតាកុង?

ខ៖ អត់ទេនៅតែខ្ញុំមួយនិង។

ក៖ នៅតែកុងមួយ។

ខ៖ បាទ!

ក៖ ហើយអញ្ជឹងបងៗកុងពីរនាក់និងទៅណាអស់ហើយកុង?

ខ៖ បងៗខ្ញុំពីរនាក់និងគាត់ស្លាប់អស់ហើយ។

ក៖ បាទ! គាត់ស្លាប់អស់ហើយកុង។អញ្ជឹងកុងគាត់ស្លាប់នៅជំនាន់ប៉ុលពតមែនកុង?

ខ៖ បាទ! គាត់ស្លាប់នៅជំនាន់ប៉ុលពតនិង។

ក៖ ដោយសារប៉ុលពតយកទៅសម្លាប់មែនកុង?

ខ៖ បាទ! គេយកទៅសម្លាប់និងហើយបងៗខ្ញុំនិង។

ក៖ បាទ!
ហើយអញ្ចឹងក្រុមគ្រួសាររបស់កុងទាំងអស់អ្នករស់នៅខេត្តកណ្ដាលនិងទាំងអស់គ្នាកុង។

ខ៖ បាទ! ខ្ញុំអ្នករស់នៅខេត្តនិងទាំងអស់គ្នានិង។

ក៖ បាទ!
ហើយអញ្ចឹងកុងមានបងប្អូនជីដូនមួយដែរមានអ្នកណាមួយដែររស់នៅក្រៅប្រទេសទេកុង?

ខ៖ អត់មានទេ។

ក៖ បាទ!
ហើយអញ្ចឹងកុងសព្វថ្ងៃនិងមានបងប្អូនហើយមានចៅទៅបម្រើការងារនៅក្រៅប្រទេសដូចជាប្រទេស ថៃ វៀតណាម កូរ៉េទេកុង។

ខ៖ អត់មានទេ។

ក៖ អត់មានទេកុង។

ខ៖ បាទ!

ក៖
ហើយអញ្ចឹងកុងបើនិយាយពីអាពាហ៍ពិពាហ៍របស់កុងវិញតើភរិយារបស់កុងមានឈ្មោះអ្វីដែរកុង?

ខ៖ ប្រពន្ធខ្ញុំមានឈ្មោះ ជេក។

ក៖ ប្រពន្ធរបស់កុងឈ្មោះ ជេក។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកុងបានរៀបអាពាហ៍ពិពាហ៍នៅណាដែរកុង?

ខ៖ បាទ! នៅខេត្តកណ្ដាលនិងម៉ងនិង។

ក៖ បាទ! នៅផ្ទះនិងម៉ងកុង។

ខ៖ បាទ! អត់នៅច្បារអំពៅនិង។

ក៖ បាទ! នៅច្បារអំពៅនៅភ្នំពេញ។

ខ៖ បាទ!

ក៖ ហើយអញ្ចឹងកុងការបានប៉ុន្មានឆ្នាំដែរកុង?

ខ៖ ការឆ្នាំ។

ក៖ កាលនិងកុងការនៅជំនាន់ប៉ុលពតនិងមែនកុង។

ខ៖ ខ្ញុំការឆ្នាំ៧៩។

ក៖ បាទ! ហើយអញ្ចឹងកុងការពេលចប់អាពតហើយការម៉ងកុង?

ខ៖ បាទ! អត់ទេខ្ញុំការពេលនិង៨៤ទៅ៨៥ទេ។

ក៖ បាទ! អញ្ចឹងការពេលនិង៨៤ទៅ៨៥ទេកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងការបានយូរដែរកុងណោះ?

ខ៖ ខ្ញុំការយូរដែរនិង។

ក៖ បាទ!
ហើយអញ្ចឹងកុងម៉ាក់យាយគាត់នៅជាមួយកុងឬក៏គាត់បានចែកឋានទៅហើយកុង។

ខ៖ អឺគាត់ស្លាប់បាត់ហើយ។

ក៖ បាទ! គាត់ស្លាប់ហើយកុង។

ខ៖ បាទ!

ក៖ អញ្ចឹងកុងស្លាប់ដោយសារអីដែរកុង។

ខ៖ គាត់ដោយសារជម្ងឺនិង។

ក៖ បាទ! អញ្ចឹងគាត់ស្លាប់ដោយសារជម្ងឺកុងហើយគាត់មានជម្ងឺអីគេដែរកុង។

ខ៖ គាត់មានជម្ងឺចាស់និង។

ក៖ បាទ! គាត់មានជម្ងឺចាស់កុង។

ខ៖ បាទ!

ក៖
ហើយអញ្ចឹងបើនិយាយពីអាពាហ៍ពិពាហ៍របស់កុងកាលនិងកុងដូចជាឪពុកម្តាយរបស់កុងជាអ្នកផ្សំផ្គុំឲ្យឬក៏កុងបានឃើញគ្នាហើយបានស្រឡាញ់គ្នានិងកុង។

ខ៖ បាទ!ឪពុកម្តាយគាត់ផ្សំផ្គុំឲ្យ។

ក៖ បាទ! អញ្ចឹងពេលនិងកុងអត់ដែរស្គាល់គ្នាសោះម៉ងកុង។

ខ៖ អត់ដែរស្គាល់គ្នាផងនិង។

ក៖ បាទ!
ហើយអញ្ចឹងកុងពេលកុងបានរៀបការនិងកុងបានជួបមុខគ្នានិងកុងមានអារម្មណ៍បែបណាដែរកុង?

ខ៖ កាលនិងមានចិត្តថាខ្មាស់ដែរនិង។

ក៖ បាទ! មានអារម្មណ៍ថាអៀនកុង។

ខ៖ បាទ! ពេលនិងអត់ដែរស្គាល់គ្នាផងនិង។

ក៖ បាទ!

ខ៖ បាទ!
អត់ដែរស្គាល់និងហើយដូចថាឪពុកម្តាយគាត់បានឃើញតហើយគាត់ចង់បានឲ្យខ្ញុំនិងណាស់។

ក៖ បាទ! ហើយពេលនិងម៉ាគាត់នៅណាដែរកុង?

ខ៖ បាទ! ពេលនិងគាត់នៅច្បារអំពៅ។

ក៖ បាទ! គាត់នៅច្បារអំពៅ។

ខ៖ បាទ! ហើយគាត់នៅព្រៃឯក ។

ក៖ អរគាត់នៅព្រៃឯក។

ខ៖ បាទ!

ក៖ បាទ!ពេលនិងកុងជួបជំនួនគាត់ប៉ុន្មានដែរកុង?

ខ៖ អត់ដឹងទេកាលណោះថ្ងៃដែរនិង។

ក៖ បាទ! កាលនិងលុយប៉ុន្មានដែរកុង?ហើយកាលនិងកុងចាយលុយឬក៏ចាយមាសកុង។

ខ៖ កាលនិងចាយលុយនិង។

ក៖ បាទ! ហើយកាលនិងកុងឲ្យគាត់បាន៣០០០រៀលឬប៉ុន្មានកុង?

ខ៖ កាលនិងប្រហែល៣០០០និងហើយ។

ក៖ បាទ! អញ្ចឹង៣០០០និងកុង។

ខ៖ បាទ! ៣០០០និងទៅ។

ក៖ បាទ! ហើយអញ្ចឹងកុងអត់ដែរស្គាល់គ្នាទេកុង។

ខ៖ បាទ!

ក៖ អត់ដែរឃើញគ្នាសោះម៉ងកុង?

ខ៖ អត់ដែរឃើញគ្នាទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអាចអានហើយអាចសរសេរភាសាខ្មែរបានល្អទេកុង?

ខ៖ ខ្ញុំចេះតែតាតែឥឡូវសរសេរអត់កើតទេ។

ក៖ បាទ! ហើយអញ្ចឹងកុងពេលនិងកុងរៀនបានថ្នាក់ទៅប៉ុន្មានដែរកុង?

ខ៖ បាទ! ពេលនិងខ្ញុំបានរៀនបឋមនិង។

ក៖ បាទ! ហើយអញ្ចឹងកុងរៀនបានថ្នាក់ទីប្រាំពីរកុង។

ខ៖ បាទ! ថ្នាក់ទី៧និងហើយពេលនិងថ្នាក់ទី១០។

ក៖ បាទ! បើកាលពីជំនាន់មុនហើយបើឥឡូវនិងកុង។

ខ៖ បើឥឡូវនិងថ្នាក់ទី៧។

ក៖ បាទ! បើឥឡូវនិងថ្នាក់ទី៧និង។

ខ៖ បាទ! ហើយពេលឥឡូវនិងថ្នាក់ទី៩ព្រោះអីខ្ញុំប្រលងជាប់ឡើងថ្នាក់ទី១០។

ក៖ អរហើយអញ្ជឹងពេលនិងកុងថ្នាក់ទី៩ហើយកុងប្រលងចប់កុងឡើងថ្នាក់ទី១០កុង?

ខ៖ បាទ! អត់ទេពេលនិងថ្នាក់ទីប្រាំបីទេ។

ក៖ បាទ! ហើយអញ្ជឹងពេលននិងកុងរៀនថ្នាក់ទី៧ទេហើយកុងត្រូវឡើងថ្នាក់ទី៨កុង។

ខ៖ បាទ!

ក៖ ហើយអញ្ជឹងកុងមានចាំថាសាលារបស់កុងពេលនិងមានឈ្មោះអីគេដែរកុង?

ខ៖ សាលាខ្ញុំពេលនិងមានឈ្មោះថា សន្ធរមុខ។

ក៖ អរកុងរៀននៅសន្ធរមុខទៀតកុង។

ខ៖ បាទ!

ក៖
ហើយអញ្ជឹងអ្នកដែររៀនសន្ធរមុខសុទ្ធតែសិស្សពូកែណាស់កុង?ហើយអញ្ជឹងកុងពេលនិង
រៀនពូកែអត់កុង។

ខ៖ បាទ! គ្មានទេមានសិស្សតិចនិង។

ក៖ ហើយអញ្ជឹងពេលនិងកុងរៀនពូកែអត់កុង?

ខ៖ តាមមុខវិជ្ជាទេ។

ក៖ បាទ!
តាមមុខវិជ្ជទេកុងណោះ។ហើយអញ្ជឹងពេលនិងកុងមានមិត្តភក្តិប៉ុន្មាននាក់ដែរកុង?

ខ៖ បាទ!មានច្រើនដែរតែបែកគ្នាអស់ហើយ។

ក៖ បាទ! ហើយដូចមិត្តភក្តិនៅក្នុងភូមិក្នុងសាលាអីអត់មានទេកុង?

ខ៖ មានតា។

ក៖ ហើយអញ្ជឹងប្រហែលប៉ុន្មាននាក់ដែរកុង?

ខ៖ ប្រហែលបួនប្រាំនាក់ដែរនិង។

កៈ អរកុងមានប្អូនប្រាំនាក់ដែរ។ហើយអញ្ចឹងកុងមានចាំឈ្មោះពួកគាត់ទេកុង?

ខៈ ភ្លេចហើយ។

កៈ បាទ! កុងភ្លេចហើយ។

ខៈ បាទ! ខ្ញុំភ្លេចហើយ។

កៈ បាទ! ហើយកុងមានប្រជួនច្រើនហើយអញ្ចឹងកុងមានការភ្លេចច្រើនតែកុងនៅចាំកាលពីសម័យប៉ុលពតដែរកុង។ហើយកុងចាំរឿងកាលពីសម័យនោះថាកុងមានការលំបាកហើយមានការជួបឧបសគ្គច្រើនដែរ។

ខៈ អឺ!

កៈ បាទ!

ខៈ អត់ចាំទេដូចខួរក្បាលដូចវាល្អក់អស់ហើយអញ្ចឹងណាស់។

កៈ បាទ! កុងហើយកុងចាំបានការលំបាកពីជំនាន់ប៉ុលពតទេកុង។

ខៈ បាទ! ហើយបើការលំបាកប៉ុន្មានជំនាន់មកហើយណាស់គ្មានអីថាលំបាកដូចជំនាន់ប៉ុលពតទេ។

កៈ បាទ! ហើយនិងចងចាំជាងគេមកណោះកុង។

ខៈ បាទ! ព្រោះកាលសម័យនិងមានការលំបាកជាងគេណាស់ហើយបានខ្ញុំចាំជាងគេនិង។

កៈ បាទ!

ខៈ បើអត់មានការលំបាកទេខ្ញុំអត់ចាំទេ។

កៈ បាទ! ហើយដូចជាជំនាន់ឥឡូវអីនិងអត់មានការលំបាកអីផងអញ្ចឹងអត់មានការចាំទេ?

ខៈ បាទ!

កៈ ហើយអញ្ចឹងកុងមានចាំសាច់រឿងជាមួយមិត្តភក្តិថាកុងមានធ្លាប់ទៅលួចបេះស្វាយជាមួយគ្នាទេកុង?

ខៈ ហោសអត់និងជារឿងធម្មតាទេ។

ក៖ បាទ! និងអាណុងជាមួយរឿងធម្មតាទេកុងហើយពេលនិងកុងច្រលើមទេកុង?

ខ៖ អត់ទេ។

ក៖ ហើយអញ្ជឹងកុងមានច្រលើមទេកុង។

ខ៖ អត់ទេ។

ក៖ អត់មានទេ។

ខ៖ ខ្ញុំគ្រាន់តែទៅវត្តហើយបេះក្តឹបគរនិង។

ក៖ បាទ! បេះក្តឹបគរគេកុង។

ខ៖ ហើយយកទៅជក់ជាមួយអំបិលនិង។

ក៖ បាទ!

ខ៖
ហើយពេលនិងខ្ញុំខ្សត់ណាស់ណាពេលនិងទៅរៀនហើយដូចក្មេងឯងសម័យឥឡូវនិងខ្ញុំសរសើរហើយមានឪកាសហើយអត់ខំរៀនអញ្ជឹងណាស់ហើយខ្ញុំប្រាប់កូនចៅខ្ញុំអញ្ជឹងណាស់ហើយខ្ញុំថាអញចាយមួយកាក់ពីរកាក់ម្តាយឲ្យកាក់និងអរចង់ងាប់ហើយនិង។

ក៖ បាទ! ហើយការនិងបើមានកង់ជិះនិងបានញ៉ែស្រីៗនិង។

ខ៖ បាទ! ហើយកាលនិងវេទនាណាស់។

ក៖ បាទ!

ខ៖
ហើយពេលនិងពេលទៅរៀននិងម្តាយឲ្យខ្ញុំទៅរៀនបានមួយកាក់ពីកាក់និងហើយអត់ដូចឥឡូវនិងទេទារនេះទារនោះអញ្ជឹងណាស់ដឹងថាអត់បានទេអញ្ជឹង។

ក៖ បាទ! ដឹងថាអត់ហើយ។

ខ៖ បាទ! ដឹងថាអត់ហើយ។

ក៖ បាទ!

ខ៖
ហើយយើងបានឈប់ពីថ្ងៃសៅរ៍ហើយនិងថ្ងៃអាទិត្យនិងហើយថ្ងៃព្រហស្បត៍និងពលកម្ម

ហើយរៀនបានច្រើនណាសហើយក្មេងឥឡូវនិងរៀនបានតិចណាស់ហើយពេលបានមកផ្ទះអញ្ចឹងណាស់មានការធ្វើទៀតគ្មានអីទៅពាក់ពន្ធ័និងខួរក្បាលយើងទេហើយខ្ញុំជួយឪពុកម្ដាយនិងទៅណាស់។

ក៖ បាទ!

ខ៖
ហើយជួយធ្វើការឪពុកម្ដាយអញ្ចឹងទៅណាស់ហើយបានលុយយកទៅរៀនហើយយើងបានចាយហើយច្រើនហើយអញ្ចឹងណាស់។

ក៖ បាទ! ៗ
ហើយអញ្ចឹងកុងដូចតាំងពីតូចរហូតដល់ធំនិងតើកុងមានធ្លាប់ស៊ីឈ្នួលគេដូចធ្វើការដកស្ទូងគេទេកុង?

ខ៖ អឺធ្លាប់តា។

ក៖ អញ្ចឹងកុងធ្លាប់កុងណោះ។

ខ៖ ថាហៃលអស់ហើយ។

ក៖ បាទ! កុងហៃលអស់ហើយកុង។

ខ៖ បាទ! ហើយធ្វើខ្ញុំគេនិង។

ក៖ បាទ! អញ្ចឹងកុងពេលនិងគេហៅអីគេទេកុងដូចបាច់ដូចម៉ាឆ្លោន។

ខ៖ អរម៉ាឆ្លោននិង។

ក៖ បាទ!ពេលនិងម៉ាឆ្លោននិងបានប៉ុន្មានតែកុង?

ខ៖ ម៉ាឆ្លោននិងបាន៥០រៀលនិង។

ក៖ បាទ! អញ្ចឹង៥០រៀលជំនាន់និងថ្លៃណាស់កុង?

ខ៖
អត់ថ្លៃប៉ុន្មានទេ។ហើយដូចស្វាយយើងវាដប់ផ្លែអញ្ចឹងណាស់ហើយស្រូវយើងនិងឆ្លោននិងវាមានដប់ស្លឹកអញ្ចឹង។

ក៖ បាទ!ៗ ហើយអញ្ចឹងកាលនិងកុងបានប្រាក់កម្រៃបានប៉ុន្មានដែរកុងកាលនិង?

ខ៖ កាលនិងបានថ្លៃ។

ក៖ ហើយកាលណុងថ្លៃហើយកុងបានប៉ុន្មានដែរកុង?

ខ៖ ថ្លៃកាលណុងបើយើងស៊ីឈ្នួលថ្ងៃគេយើងបានថ្ងៃបាន២០០០អីគេណុង។

ក៖ អរបានមួយថ្ងៃ២០០០កុងណោះ។

ខ៖ និងហើយ។

ក៖ បាទ! ថ្លៃដែរកុងណោះ។

ខ៖ បាទ!

ក៖
ហើយអញ្ចឹងកុងដូចតាំងពីតូចរហូតដល់ធំអញ្ចឹងតើកុងមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងជីវិតរបស់កុងមានការលំបាកហើយពេលកុងមានគ្រួសារថាកុងមានជួបឧបសគ្គអ្វីខ្លះនៅក្នុងជីវិតរបស់កុងណាស់កុង?

ខ៖ វាមានឧបសគ្គនិងហើយគ្រាន់ផ្លាស់ប្តូរពីរបបមួយទៅមួយវាអញ្ចឹងអី?

ក៖ បាទ!

ខ៖ ហើយបើគេផ្លាស់ប្តូររបបថ្មីទៅហើយយើងបានសប្បាយដូចគេទៅ។

ក៖ បើគេផ្លាស់ប្តូររបបថ្មីទៅបានសប្បាយដូចគេទៅ។

ខ៖ ហើយគេធ្វើមិចយើងធ្វើអញ្ចឹងទៅ។

ក៖ បាទ!

ខ៖ ហើយខ្ញុំនិយាយពីអារបបចាស់និង។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីមុខម្ហូបវិញហើយកុងចូលចិត្តមុខម្ហូបអីជាងគេកុង?

ខ៖ ខ្ញុំខ្មែរអញ្ចឹង។

ក៖ បាទ! ដូចជាសម្លម្ជូល ហើយស្រលឹក ប្រហើរ ប្រហុកជញ្ជាំម អញ្ចឹងកុង។

ខ៖ បើនិយាយពីប្រហុកជញ្ជាំមនិងខ្ញុំចូលចិត្តណាស់ហើយឆ្ងាញ់

ក៖ បាទ! វាឆ្ងាញ់កុង។

ខ៖ បាទ!

ក៖ និងម្ហូបដែរកុងចូលចិត្តជាងគេកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ជឹងកុងបើនិយាយពីល្បែងប្រជាប្រិយភាពវិញកុងដូចជាលាក់កន្សែង ចោលឈូង ទាញ់ព្រ័ត អីកុងចូលចិត្តទេកុង?

ខ៖ អានិងល្បែងពីដើមមកពេលចូលឆ្នាំខ្មែរយើងនិង។

ក៖ បាទ! ដូចតាំងពីក្មេងមកកុង?

ខ៖ ហើយចោលឈូសអីនិងអត់ដូចឥឡូវអីទេ។

ក៖ បាទ!

ខ៖ ពិបាកម៉ង។

ក៖ បាទ!

ខ៖ ហើយស្រីៗពីជំនាន់និង១៦ទៅ១៧ងឹកទឹកស្រោតឥឡើយនិង?

ក៖ បាទ! ហើយអញ្ជឹងកុងមានដែរធ្លាប់ទៅលួចមើលគេកុង?

ខ៖ ហើយអាណុងធម្មតាវាធ្វើមិច។

ក៖ ហើយអញ្ជឹងធម្មតាកុងណោះ។

ខ៖ ហើយមកមើលក្មេងជំនាន់ឥឡូវនិង។

ក៖
ហើយអញ្ជឹងកុងនៅពេលចូលឆ្នាំខ្មែរម្តងៗកុងមានទៅវត្តហើយរាំនៅវត្តឃើញកូនក្រមុំគេ ហើយតាមញ៉ែដល់ផ្ទះទេកុង?

ខ៖ អត់ទេអត់អញ្ជឹងទេ។

ក៖ អត់អញ្ជឹងទេកុង?

ខ៖ បាទ!
ប្អូនគេប្អូនយើងហើយកូនគេកូនយើងនិងដើរទៅណាអញ្ចឹងគេដើរជាមួយម្ដាយគេហើយយើងអត់ទៅជាមួយគេទេណា។

ក៖ បាទ!

ខ៖ ហើយមិនអាចធ្វើអញ្ចឹងបានទេមនុស្សជំនាន់មនុស្សត្រង់ណាស់។

ក៖ បានកាលនិងមនុស្សជំនាន់គេត្រង់ណាស់កុង។

ខ៖ បាទ!

ក៖ ហើយនិយាយពីច្រៀងហើយនិងរាំវិញកុងចូលចិត្តទេកុង?

ខ៖ បើនិយាយពីច្រៀងនិងអាណុងការសប្បាយ។

ក៖ បាទ! ហើយអញ្ចឹងកុងចូលចិត្តប៉ុន្មានបទដែរកុង?

ខ៖ ច្រើនណាស់។

ក៖ បើនិយាយពីតារាតែនៅក្នុងដួងចិត្តពីណាគេកុងហើយដូចជាលោក ស៊ីម ស៊ីសាមុតនិងចូលចិត្តទេកុង?

ខ៖ ចូលចិត្តតា។

ក៖ បាទ!
ហើយអញ្ចឹងកុងបើនិយាយថាកូនចៅរបស់កុងនិងមានអ្នកណាគេចេះលេងឧបករណ៍តន្ត្រីដូចជា ស្គរ រនាត ហ្គីតា ព្យាណូ ខ្លុយ?

ខ៖ អត់។

ក៖ បាទ! អត់មានទេកុង?

ខ៖ អត់ទេ។

ក៖
ហើយអញ្ចឹងកុងបើនិយាយពីសភាពផ្ទះរបស់កុងកាលពីជំនាន់និងកុងមានលក្ខណៈបែបណាដែរកុងហើយផ្ទះឈើគ្បឿងឬផ្ទះខ្ទមកុង?

ខ៖ ផ្ទះគ្បឿង។

កៈ បាទ! គ្បឿងកុង។

ខៈ បាទ!ផ្ទះឪពុកម្ដាយខ្ញុំនិង។

កៈ បាទ! ហើយជញ្ជាំងអីគេដែរកុង?

ខៈ ហើយជញ្ជាំងក្ដានិងហើយកាលនិងផ្ទះគ្បឿងជញ្ជាំងក្ដានិង។

កៈ បាទ! ហើយអញ្ចឹងជើងសសរវិញកុង?

ខៈ ហើយជើងសសរនិងឈើនិង។

កៈ ហើយអញ្ចឹងរណាបឈើដែរកុង?

ខៈ បាទ! ឈើដែរនិង?

កៈ ហើយឈើអាស្សីឬក៏ឈើកុង?

ខៈ ឈើក្ដាយើងនិងឈើច្រៀកនិង។

កៈ ហើយអញ្ចឹងកុងបើកាំជណ្ដើរអីគេដែរកុង?

ខៈ បើកាំជណ្ដើរនិងឈើដែរនិង?

កៈ បាទ! ឈើដែរ។

ខៈ ផ្ទះនិងឈើទាំងអស់និងគ្មានស៊ីម៉ងន៍ទេ។

កៈ បាទ! ហើយអញ្ចឹងកុងដូចឪពុកម្ដាយរបស់កុងធ្វើផ្ទាល់ឬគាត់ជួលគេធ្វើកុង?

ខៈ អត់ទេជួលគេទាំងអស់ម៉ៅគេទាំងអស់និង។

កៈ អត់ម៉ៅគេកុង។

ខៈ
បើនិយាយពីដើមមកផ្ទះឪពុកខ្ញុំនិង១៦រៀលនិង។ហើយមិនមែន១៦រៀលឥឡូវនិងទេណាស់។

កៈ បាទ! មិនមែន១៦រៀលឥឡូវទេ១៦រៀលជំនាន់មុន។

ខៈ និងហើយ។ហើយគេប្រើកាក់សេននិង។

កៈ បាទ! បានកាលនិងកាក់សេននិងកុង។

ខៈ បាទ!

កៈ ហើយអញ្ជឹងកុងមានចេះវេនតពីឪពុកម្ដាយដូចជាក្ងរស្កុរត្នោត ត្បាញកន្ទេល ត្បាញក្រមាអញ្ជឹងកុងមានចេះទេកុង?

ខៈ អត់ទេ។

កៈ អត់ចេះទេកុង។

ខៈ បាទ!

កៈ
ហើយអញ្ជឹងកុងមានក្ដីស្រមៃថាកុងពេលកុងធំឡើងហើយមានចំណេះដឹងហើយតើកុងមានក្ដីស្រមៃថាកុងចង់ក្លាយជាលោកគ្រូបង្រៀន គ្រូពេទ្យ ទាហាន ប៉ូលិសទេកុង?

ខៈ ឥឡូវនិងខ្ញុំចាស់ហើយនិង។

កៈ អត់ទេកុងកាលកុងនៅពីក្មេងណាស់កុង?

ខៈ អត់មានទេ។

កៈ បាទ! អញ្ជឹងកុងអត់មានក្ដីស្រមៃទេកុង?

ខៈ អត់មានទេ។

កៈ បាទ!
ហើយអញ្ជឹងជាចុងក្រោយកុងមានពាក្យពេចន៍អីចង់ផ្ដាំផ្ញើរទៅកូនចៅជំនាន់ក្រោយឲ្យគាត់ខិតខំប្រឹងរៀនអញ្ជឹងកុង?

ខៈ
ហើយអញ្ជឹងបានខ្ញុំនិយាយតែគ្មានប្រយោជន៍ទេអញ្ជឹងណាស់ហើយបើអាកូនចៅវាអត់គិតហើយក្មេងឥឡូវពិបាកណាស់យើងនិយាយទៅអត់ស្ដាប់អញ្ជឹងណាស់។

កៈ បាទ!

ខៈ
ហើយខ្ញុំប្រាប់ថាឃើញម៉ែឪធ្វើស្រែធ្វើចំការអញ្ជឹងណាស់មានការលំបាកហើយអញ្ជឹងបាន

ប្រាប់វាថាខំប្រឹងរៀនទៅទាន់ខ្លួននៅក្មេងណាស់ហើយទាន់អាងមានម៉ែឪឯងមានកម្លាំងរកលុយឲ្យឯងរៀនណាស់ហើយគ្មានអីធំជាងរៀនទេហើយមានចំណេះបានទៅរួច។

ក៖ បាទ!

ខ៖
ហើយខំប្រឹងទៅដើម្បីអនាគតហើយមានចំណេះមានភាពថ្លៃថ្នូរហើយបើអត់ប្រឹងរៀនទេពិបាកតាំងខ្លួនឯងហើយពិបាកដល់ប្រពន្ធកូនខ្លួនឯងនិងទៀត។

ក៖ បាទ!

ខ៖ ត្រូវអត់ក្មួយ។

ក៖ បាទ!
ហើយអញ្ចឹងបើកុងចង់ឲ្យគាត់ជៀសវាងពីអ្វីមួយដូចជាគ្រឿងញៀនហើយល្បែងស៊ីសងហើយបងតូចបងធំទេកុង?

ខ៖
ហើយខ្ញុំប្រាប់ថាអាវាជៀសឲ្យផុតពីពួកម៉ាកនិងកាលសែពគប់ជាមួយមនុស្សល្អបានល្អទៅហើយបើសែពគប់ជាមួយមនុស្សមិនល្អបានមិនល្អនិង។

ក៖ ហើយអញ្ចឹងកុងមានពាក្យអីចងផ្ដាំផ្ញើរអីទៀតទេកុង?

ខ៖
អត់មានទេមានតែប៉ុណ្ណឹងទេ?ហើយខ្ញុំគ្រាន់ថាខ្ញុំប្រាប់កូននិងខំបណ្ដុះបណ្ដាលកូនហើយកុំបណ្ដាលវាហើយឲ្យសង្គមគេមើលងាយហើយកុំដើរជាមួយមនុស្សគ្មានពូជគ្មានសប្បុរនិងហើយដើរជាមួយអ្នកមានពូជមានសប្បុរអញ្ចឹងណាស់។ហើយមនុស្សខុសគ្នាហើយមានមនុស្សបីបួននាក់មកអង្គុយជិតខ្ញុំនិងហើយខ្ញុំប្រាប់ថាកុំបណ្ដាលកូនហើយមើលអនាគតខ្លួនឯងមើលហើយមើលអ
នាគតកូនមើលហើយខ្ញុំនិយាយទៅខឹងខ្ញុំហើយខ្ញុំថាអត់ចេះធ្វើល្ងង់ទៅ។

ក៖ បាទ! ហើយអញ្ចឹងមានតែប៉ុណ្ណឹងទេកុង។

ខ៖ បាទ!

ក៖
ហើយជាចុងក្រោយខ្ញុំសូមអរគុណកុងដែរបានអនុញ្ញាតឲ្យធ្វើការសម្ភាសន៍អំពីជីវប្រវត្តិរប

ស់កុងអញ្ជឹងណាស់កុងហើយអញ្ជឹងសូមឲ្យកុងមានសុខភាពល្អហើយមានអាយុវែង។ហើយអញ្ជឹងជាចុងក្រោយខ្ញុំអនុញ្ញាតកុងយកសម្លេងរបស់កុងទៅឲ្យសាលាបានអត់កុង?

ខ៖ មានអីទេ។

ក៖ ហើយអញ្ជឹងអរគុណកុងមកកាន់សាលា b y u
យើងខ្ញុំហើយអញ្ជឹងខ្ញុំអរគុណកុងជំរាបលា។